ធានារ៉ាប់រងសុខភាពជាតិ (NHI)៖ ប្រព័ន្ធដែលបម្រើជាផ្នែងខ្លួងនៃសេវាថែទាំសុខភាពនៅប្រទេសជប៉ុន

ប្រព័ន្ធនេះធានាថាអ្នកនិងក្រុមគ្រួសារអ្នកអាចទទួលបានសេវាថែទាំសុខភាពក្នុងករណីមានជំងឺឬរបួស។

អ្នកដែលរស់នៅក្នុងប្រទេសជប៉ុន ដោយមិនគិតពីសញ្ជាតិ ត្រូវមានកាតព្វកិច្ចចុះឈ្មោះចូលប្រព័ន្ធធានារ៉ាប់រងសុខភាពសាធារណៈ។ ទោះបីជាការបង់បុព្វលាភធានារ៉ាប់រងជាកាតព្វកិច្ចដើម្បីទទួលបានការធានារ៉ាប់រងក៏ដោយ ប្រព័ន្ធនេះធានាថាអ្នកនិងក្រុមគ្រួសារអ្នកអាចទទួលបានសេវាថែទាំសុខភាពក្នុងករណីមានជំងឺឬរបួស ដោយកាត់បន្ថយបន្ទុកចំណាយរបស់អ្នក។

គុណប្រយោជន៍នៃធានារ៉ាប់រងសុខភាពសាធារណៈ:

- នៅពេលអ្នកទៅមន្ទីរពេទ្យឬគ្លីនិក ជាធម្មតាអ្នកចំណាយត្រឹមតែ 30% នៃការចំណាយព្យាបាលសរុបប៉ុណ្ណោះ។ ធានារ៉ាប់រងនេះគ្របដណ្តប់ 70% ដែលនៅសល់ ដែលកាត់បន្ថយការចំណាយព្យាបាលរបស់អ្នកបានយ៉ាងច្រើន។
- ធានារ៉ាប់រងផ្តល់នូវកម្មវិធីបន្ថែមដើម្បីជួយការពារជីវិតប្រចាំថ្ងៃរបស់អ្នក ដូចជាការគាំទ្រផ្នែកហិរញ្ញវត្ថុក្នុងករណីមានការចំណាយលើការព្យាបាលខ្ពស់។

ប្រភេទនៃធានារ៉ាប់រងសុខភាពសាធារណៈខុសគ្នាអាស្រ័យលើការងារ និងអាយុរបស់អ្នក។ ធានារ៉ាប់រងសុខភាពជាតិ ភាគច្រើនគឺសម្រាប់អ្នកដែលមិនត្រូវបានរ៉ាប់រងដោយធានារ៉ាប់រងសុខភាពនិយោជិត ឬប្រព័ន្ធវេជ្ជសាស្ត្រសម្រាប់មនុស្សដែលមានអាយុ 75 ឆ្នាំឡើងទៅ។ អ្នកដែលមានសិទ្ធិចូលរួមធានារ៉ាប់រងនេះ រួមទាំងបុគ្គលស្វ័យនិយោជន៍ សិស្សនិស្សិត អ្នកគ្មានការងារធ្វើ និងជនបរទេសដែលស្នាក់នៅក្នុងប្រទេសជប៉ុនលើសពីបីខែ គឺត្រូវបានតម្រូវឱ្យចុះឈ្មោះចូលធានារ៉ាប់រងនេះ។

តើអ្នកណាខ្លះត្រូវបានតម្រូវឱ្យចុះឈ្មោះចូលធានារ៉ាប់រងសុខភាពជាតិ?


អ្នកត្រូវបានតម្រូវឱ្យចុះឈ្មោះចូលធានារ៉ាប់រងសុខភាពជាតិ ប្រសិនបើអ្នករស់នៅក្នុងប្រទេសជប៉ុន ហើយចូលក្នុងប្រភេទណាមួយដូចខាងក្រោម។



តើធានារ៉ាប់រងសុខភាពជាតិទទួលបានហិរញ្ញប្បទានយ៉ាងដូចម្តេច?

តើការចំណាយលើការព្យាបាលត្រូវបានគាំទ្រយ៉ាងដូចម្តេច?

ការចំណាយលើការព្យាបាលក្រោមធានារ៉ាប់រងសុខភាពជាតិ ត្រូវបានផ្តល់មូលនិធិដោយបុព្វលាភធានារ៉ាប់រង ដែលបង់ដោយសមាជិក និងដោយមូលនិធិសាធារណៈ រួមទាំងចំណូលពន្ធ។ ប្រហែលពាក់កណ្តាល (50%) នៃការចំណាយលើការព្យាបាលសរុបក្រោមប្រព័ន្ធធានារ៉ាប់រងសុខភាពជាតិ ត្រូវបានផ្តល់មូលនិធិដោយមូលនិធិសាធារណៈ។



ធានារ៉ាប់រងនេះផ្តល់នូវប្រព័ន្ធមួយដែលសង្គមទាំងមូលគាំទ្រដល់សេវាថែទាំសុខភាព ហើយទន្ទឹមនឹងនេះកាត់បន្ថយបន្ទុកលើបុគ្គលម្នាក់ៗ។

អត្ថប្រយោជន៍ដែលផ្តល់ដោយធានារ៉ាប់រងសុខភាពជាតិ និងរបៀបទទួលសេវាថែទាំសុខភាព

ប្រសិនបើអ្នកបានចុះឈ្មោះចូលធានារ៉ាប់រងសុខភាពជាតិ សូមបង្ហាញកាត My Number ឬវិញ្ញាបនបត្រសិទ្ធិទទួលបានធានារ៉ាប់រងសុខភាពរបស់អ្នកនៅបញ្ជរទទួលភ្ញៀវនៅពេលអ្នកទទួលការព្យាបាលសម្រាប់ជំងឺឬរបួសនៅតាមស្ថាប័នវេជ្ជសាស្ត្រ។ ជាធម្មតាអ្នកចាំបាច់ត្រូវបង់ត្រឹមតែមួយផ្នែក (ជាធម្មតា 30%) នៃការចំណាយលើការព្យាបាល។

ក្រោមធានារ៉ាប់រងសុខភាពជាតិ អ្នកអាចទទួលបានអត្ថប្រយោជន៍ដូចខាងក្រោម។

- សេវាថែទាំសុខភាពដូចជាការពិគ្រោះយោបល់ ការព្យាបាល និងការចេញវេជ្ជបញ្ជានៅតាមស្ថាប័នវេជ្ជសាស្ត្រ
- ការចំណាយលើអាហារកំលុងពេលសម្រាកព្យាបាលនៅមន្ទីរពេទ្យ
- អត្ថប្រយោជន៍នៃចំណាយព្យាបាលតម្លៃខ្ពស់៖ ប្រសិនបើការចំណាយលើការព្យាបាលដែលអ្នករ៉ាប់រងបន្តកគឺខ្ពស់ខ្លាំង ទឹកប្រាក់ដែលលើសពីកម្រិតកំណត់ជាក់លាក់មួយនឹងត្រូវបានសងវិញ។

សមាជិកនៃធានារ៉ាប់រងសុខភាពជាតិត្រូវតែបង់បុព្វលាភធានារ៉ាប់រង។

បុព្វលាភធានារ៉ាប់រងត្រូវបានគណនាដោយផ្អែកលើប្រាក់ចំណូលឆ្នាំមុន និងស្ថានភាពគ្រួសាររបស់អ្នក។ ទឹកប្រាក់បុព្វលាភនិងវិធីសាស្ត្រគណនាគឺខុសគ្នាពីរដ្ឋបាលមូលដ្ឋានមួយទៅមួយ។

ប្រសិនបើអ្នកមិនបង់បុព្វលាភ រដ្ឋបាលមូលដ្ឋានរបស់អ្នកនឹងផ្ញើសេចក្តីជូនដំណឹងរំលឹកដល់អ្នក។

ប្រសិនបើអ្នកមិនបង់ក្នុងរយៈពេលយូរ អ្នកអាចនឹងប្រឈមមុខនឹងផលវិបាកដូចខាងក្រោម។

- ទ្រព្យសម្បត្តិរបស់អ្នកអាចនឹងត្រូវបានរឹបអូស។
- អត្ថប្រយោជន៍របស់អ្នកអាចត្រូវបានដាក់កម្រិត។ អ្នកអាចនឹងចាំបាច់ត្រូវបង់ថ្លៃព្យាបាលពេញនៅស្ថាប័នវេជ្ជសាស្ត្រ។ ក្នុងករណីនេះ អ្នកនឹងទទួលបានសំណងវិញ ប្រសិនបើអ្នកបំពេញលក្ខខណ្ឌមួយចំនួន។
- ស្ថានភាពបង់របស់អ្នកនឹងត្រូវបានយកមកពិចារណានៅពេលអ្នកបន្តរយៈពេលស្នាក់នៅរបស់អ្នកនៅក្នុងប្រទេសជប៉ុន ឬផ្លាស់ប្តូរលក្ខណៈសម្បត្តិស្នាក់នៅរបស់អ្នក។

សូមបង់បុព្វលាភរបស់អ្នកតាមថ្ងៃកំណត់។

សំណួរចម្លើយ

សំណួរទី 1 ខ្ញុំបានមកដល់ប្រទេសជប៉ុនពីប្រទេសមួយដែលមានកិច្ចព្រមព្រៀងសន្តិសុខសង្គមជាមួយប្រទេសជប៉ុន។ តើខ្ញុំចាំបាច់ត្រូវចុះឈ្មោះចូលធានារ៉ាប់រងសុខភាពជាតិទេ?

ក្នុងករណីខ្លះ អ្នកអាចនឹងមិនចាំបាច់ចុះឈ្មោះចូលធានារ៉ាប់រងសុខភាពជាតិទេ។ សូមទាក់ទងការិយាល័យធានារ៉ាប់រងសុខភាពជាតិនៃរដ្ឋបាលមូលដ្ឋានរបស់អ្នក ហើយសួរថាតើអ្នកត្រូវចុះឈ្មោះចូលឬទេ។

សំណួរទី 2 តើថ្ងៃផុតកំណត់សម្រាប់ការចុះឈ្មោះចូលធានារ៉ាប់រងសុខភាពជាតិ បន្ទាប់ពីខ្ញុំចូលនិវត្តន៍ហើយចាកចេញពីធានារ៉ាប់រងសុខភាពនិយោជិត គឺនៅពេលណា?

សូមបំពេញបែបបទចាំបាច់នៅការិយាល័យធានារ៉ាប់រងសុខភាពជាតិនៃរដ្ឋបាលមូលដ្ឋានរបស់អ្នកក្នុងរង្វង់ 14 ថ្ងៃ។

សំណួរទី 3 តើខ្ញុំគួរធ្វើដូចម្តេចនៅពេលខ្ញុំមានការលំបាកក្នុងការបង់បុព្វលាភធានារ៉ាប់រង?



ប្រសិនបើអ្នកមានការលំបាកក្នុងការបង់បុព្វលាភ ឬចំណាយព្យាបាលដែលអ្នកត្រូវរ៉ាប់រងបន្តកដោយសារតែហេតុផលហិរញ្ញវត្ថុ អ្នកអាចនឹងទទួលបានការកាត់បន្ថយឬបង់ជាដំណាក់កាល។ ក្នុងករណីបែបនេះ សូមពិគ្រោះជាមួយការិយាល័យរដ្ឋបាលមូលដ្ឋានក្នុងតំបន់របស់អ្នកឱ្យបានឆាប់តាមដែលអាច។